

# ងើយមើលលើ

Let's Read
The Asia Foundation



នៅលើមេឃនាពេលព្រឹកព្រលឹម
ចាបស្រែកឃ្លានកំពុងហើររកអីឆី
មានមួយពាំបាន
ដង្កូវធាត់មួយជាចំណី!



មេអំបៅពណ៌ចម្រុះឆើតឆាយ
មកពីជិតឆ្ងាយរេរាំទំលើផ្កា
មេអំបៅមួយខុសពីគេ
រកឃើញទេ មេអំបៅតែមួយពណ៌។



ខ្លែងហោះពត់ពេន
យ៉ាងរីករាយ
តែខ្លែងមួយដូចជាខុសគេ
តើប្អូនអាចរកខ្លែងនោះឃើញដែរឬទេ?



រាងការ៉េធំ រាងការ៉េតូច មាននៅគ្រប់កន្លែង
មានចម្រឹងមួយខុសគេតែឯង
លាក់ខ្លួននៅត្រង់ណា ត្រង់នេះឬត្រង់នោះ?



មើលស្លឹកបៃតងទាំងនោះចុះ
នៅលើដើមឈើធំចំណាស់នុះ
មានមែកមួយពណ៌ប្លែកខុស
មួយនោះនៅត្រង់ណា?



យន្តហោះ ឆ្វាត់ឆ្វែង
ពីក្រោយមានផ្សែងរាងត្រង់ភ្លឹង
តែមានមួយផ្សែងខុសពីគេឯង
គឺមានផ្សែងកោងចុះឡើង។



ចាបទំលើខ្សែស្រែកចេចចាច
មានមួយស្ងៀមស្ងាត់មិនឮមាត់
តើចាបមួយណាឱ្យប្រាកដ
មិនឮមាត់ចេចចាចដូចគេ?



ដុំពពក ដុំពពកស
ចែងចាំងល្អលើមេឃរដូវប្រាំង
តែពពកមួយមិនចង់រាំង
ទម្លាក់ភ្លៀងតែឯងមិនខ្វល់ពីគេ។



ពេលថ្ងៃកន្លងទៅ
យប់ចូលមកដល់
អំពូលតាមថ្នល់មានពន្លឺ
មានមួយពណ៌ភ្លឺដូចព្រះអាទិត្យ។



ប្រចៀវដេកនៅពេលថ្ងៃ
ភ្ញាក់វិញពេលយប់។
មានមួយខុសគេដេកមិនឈប់
ទោះយប់ហើយនៅមិនភ្ញាក់។



នៅក្នុងលំហមានភពច្រើនអនេក
មានពន្លឺចាំងភ្លឺផ្លេក
ឃើញភពមួយខុសចម្លែក
មានខ្សែវ័ណ្ឌព័ទ្ធជុំវិញ។

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*Look Up*, Published by Pratham Books, © Pratham Books. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/
Contributing translators: Prum Kunthearo